# ការគាំទ្រ ?

វាជា ការងាយស្រួលបំផុតជ្រើសយកការគាំទ្រ សម្រាប់អ្វីមួយ ព្រោះការគាំទ្រ វាគ្រាន់តែជាការធ្វើត្រាប់។ ការធ្វើត្រាប់ មានបីប្រការ : ឬ ធ្វើត្រាប់ដោយប្រើអធ្យោបាយខុសគ្នា ឬ ប្រើវត្ថុខុសគ្នា ឬ ប្រើវិធីខុសគ្នា។ អ្នកធ្វើត្រាប់ អ្នកខ្លះធ្វើត្រាប់ដោយប្រើសិល្បៈ អ្នកខ្លះទៀត តាមទម្លាប់។ ដូច្នេះ លក្ខណវិនិច្ឆ័យ នៃការគាំទ្រ វាមានបីយ៉ាងខុសគ្នាដែរ : មធ្យោបាយ, វត្ថុ និង វិធី។ នៅក្នុងបរិបទខ្មែរ ពួកឧកញ៉ា ប្រើមធ្យោបាយលុយ ហើយនាំគ្នាធ្វើត្រាប់តាមចរិត របស់ពួកមន្ត្រីពុករលួយ, ពួកគាំទ្រនៅតាមមូលដ្ឋាន និង ថ្នាក់ដឹកនាំជាន់ខ្ពស់ ប្រើវត្ថុផ្សេងៗគ្នា ដូចយ៉ាងពាហុយុទ្ធ និង អាវុធ ហើយធ្វើត្រាប់តាមមេសាហាវ ដែលរក្សាពួកគេ, ពួកតុលាការ ប្រើនីតិវិធីក្លែង ហើយធ្វើត្រាប់តាមការចង់បាន របស់អ្នកកាន់អំណាចផ្តាច់ការ។ តែពួកទាំងបីក្រុមនាំគ្នាគាំទ្រ តាមទម្លាប់ល្ងង់ ព្រោះគ្មានប្រាជ្ញា ប្រើសិល្បៈបញ្ញាដែលនាំបង្ហាញ នូវរូបភាព នៃរបបដឹកនាំជារបបលួច គឺគិតតែពីលួច : សម្តេចស៊ីច្រើន ថីស៊ីតិច នូវ បង្កើតសំបុក នៃសព្វអំពើទុច្ចរិត នាំឲស្រុកខ្មែរក្លាយជាស្រុកអបាយ។ សួរថា គណបក្សប្រឆាំង ដែលពួកអ្នកគាំទ្រ មានជំនឿថា មានមេទ័ពពិទ័ត្ន (ប្រសប់) យល់កិច្ចកលជាក់ បញ្ឆោតពួកខ្មាំងជាតិ ឲឡប់សតិទៅជាឆ្កួត ទើបប្រើប្រាជ្ញាវាយខ្មាំងយកឈ្នះជូនជាតិ តើនាំគ្នាប្រើសិល្បៈបញ្ញាតាម វត្ថុ វិធី និង មធ្យោបាយ បែបណាដើម្បីជួយធ្វើឲបានសម្រេច នូវជ័យជំនះនោះ ?